**សន្លឹកព័ត៌មានស្តីពីថ្នាំវ៉ាក់សាំង** CAMBODIAN

# ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B
## *តើលោកអ្នកត្រូវដឹងអ្វីខ្លះ*

Many Vaccine Information Statements are available in Khmer and other languages. See www.immunize.org/vis
**សេចក្តីថ្លែងការណ៍នៃព័ត៌មានអំពីថ្នាំវ៉ាក់សាំងជាច្រើនគឺអាចរកបានជាភាសាខ្មែរ និងភាសាផ្សេងទៀត។ ចូលមើល**
www.immunize.org/vis

## 1 ហេតុអ្វីត្រូវចាក់ថ្នាំវ៉ាក់សាំង?

ជំងឺរលាកថ្លើមប្រភេទ B គឺជាជំងឺធ្ងន់ធ្ងរដែលប៉ះពាលដល់ថ្លើម។ ជំងឺនេះបង្កឡើងដោយមេរោគជំងឺរលាកថ្លើមប្រភេទ B។ ជំងឺរលាកថ្លើមប្រភេទ B អាចបណ្តាលឲ្យកើតជំងឺស្រាលដែលកើតឡើងសម្រាប់រយៈពេលប៉ុន្មានសប្តាហ៍ ឬអាចបណ្តាលឲ្យកើតជំងឺធ្ងន់ធ្ងរអស់មួយជីវិត។

ការឆ្លងមេរោគជំងឺរលាកថ្លើមប្រភេទ B អាចមានលក្ខណៈធ្ងន់ធ្ងរ ឬរ៉ាំរ៉ៃ។

**ការឆ្លងមេរោគជំងឺរលាកថ្លើមប្រភេទ B ធ្ងន់ធ្ងរ**គឺជាការឈឺរយៈពេលខ្លី ដែលកើតឡើងក្នុងរយៈពេល 6 ខែដំបូង បន្ទាប់ពីជនណាម្នាក់ឆ្លងមេរោគជំងឺរលាកថ្លើមប្រភេទ B។ ជំងឺនេះអាចបណ្តាលឲ្យ៖
- គ្រុនក្តៅ នឿយហត់ ការបាត់បង់ចំណង់អាហារ រោគចង់ក្អួត និង/ឬឈឺរោគក្អួត
- រោគលឿង (ស្បែក ឬភ្នែកលឿង ទឹកនោមព៌ណខ្មៅ ការបន្ទោរបង់លាមកព៌ណប្រផេះ)
- ឈឺចុកចាប់សាច់ដុំ សន្លាក់ និងក្រពះ

**ការឆ្លងមេរោគជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ**គឺជាការឈឺរយៈពេលយូរ ដែលកើតឡើង នៅពេលមេរោគជំងឺរលាកថ្លើមប្រភេទ B បន្តស្ថិតនៅក្នុងរាងកាយមនុស្ស។ មនុស្សភាគច្រើនដែលបន្តទៅកើតជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ មិនមានរោគសញ្ញាទេ ប៉ុន្តែ វានៅតែជាករណីធ្ងន់ធ្ងរណាស់ ហើយអាចបណ្តាលឲ្យ៖
- ខូចថ្លើម (ជំងឺក្រិនថ្លើម)
- ជំងឺមហារីកថ្លើម
- ការស្លាប់បាត់បង់ជីវិត

មនុស្សដែលមានជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃអាចចម្លងមេរោគជំងឺរលាកថ្លើមប្រភេទ B ទៅអ្នកដទៃទៀត បើទោះបីជាពួកគេហាក់បីដូចជាមិនឈឺ ឬគ្មានអារម្មណ៍ឈឺក៏ដោយ។ មនុស្សដល់ទៅ 1.4 លាននាក់នៅសហរដ្ឋអាមេរិក អាចមានជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ។ កុមារប្រហែល 90% ដែលកើតជំងឺរលាកថ្លើមប្រភេទ B ក្លាយជាជំងឺរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ ហើយមនុស្សប្រហែល 1 ក្នុងចំណោម 4 នាក់ស្លាប់បាត់បង់ជីវិត។

ជំងឺរលាកថ្លើមប្រភេទ B ឆ្លង នៅពេលឈាម ទឹកកាម ឬវត្ថុរាវនៃរាងកាយដទៃទៀត ដែលមានមេរោគជំងឺរលាកថ្លើមប្រភេទ B ចូលទៅក្នុងខ្លួនមនុស្សណាម្នាក់ ដែលមិនកើតជំងឺនេះ។ មនុស្សអាចឆ្លងមេរោគនេះ តាមរយៈ៖
- ការសម្រាកកូន (ទារក ដែលម្តាយកើតជំងឺរលាកថ្លើមប្រភេទនេះ អាចចម្លងមេរោគជំងឺនេះនៅពេល ឬក្រោយពេលសម្រាលកូន។
- ការប្រើវត្ថុ ដូចជា កាំបិតកោរ ឬច្រាស់ដុសធ្មេញ រួមគ្នាជាមួយនឹងអ្នកកើតជំងឺនេះ
- ប៉ះពាល់ឈាម ឬដំបៅរបស់អ្នកកើតជំងឺនេះ
- រួមភេទជាមួយអ្នកកើតជំងឺនេះ
- ប្រើម្ជុល ស៊ីរ៉ាំង ឬគ្រឿងបរិក្ខាចាក់ថ្នាំដទៃទៀតរួមគ្នា
- ប៉ះពាល់ឈាមពីក្បាលម្ជុល ឬឧបករណ៍មុតស្រួចដទៃទៀត

ក្នុងមួយឆ្នាំ មនុស្សប្រហែល 2,000 នាក់ នៅសហរដ្ឋអាមេរិកស្លាប់បាត់បង់ជីវិត ដោយសារតែជំងឺថ្លើម ដែលពាក់ព័ន្ធនឹងជំងឺរលាកថ្លើមប្រភេទ B។

**ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B**អាចបង្ការជំងឺរលាកថ្លើមប្រភេទ B និងផលវិបាកនៃជំងឺរលាកថ្លើមប្រភេទ B នេះ ដែលរាប់បញ្ចូលទាំងជំងឺមហារីក និងជំងឺក្រិនថ្លើម។

## 2 ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B

ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B ត្រូវបានផលិតចេញពីធាតុផ្សំនៃមេរោគជំងឺរលាកថ្លើមប្រភេទ B។ ថ្នាំវ៉ាក់សាំងនេះមិនអាចបណ្តាលឲ្យឆ្លងជំងឺរលាកថ្លើមប្រភេទ B ឡើយ។ ជាធម្មតា ថ្នាំវ៉ាក់សាំងនេះត្រូវចាក់ 2, 3 ឬ 4 ដងក្នុងរយៈពេលពី 1 ទៅ 6 ខែ។

**ទារក** គួរទទួលថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B ដូសទីមួយនៅពេលកើត ហើយជាធម្មតា នឹងទទួលដូសថ្នាំគ្រប់ចំនួន នៅអាយុ 6 ខែ។

**កុមារ និងក្មេងជំទង់**ទាំងអស់ ដែលមានអាយុតិចជាង 19 ឆ្នាំ ដែលមិនទាន់ទទួលថ្នាំវ៉ាក់សាំង ក៏គួរទៅចាក់ថ្នាំវ៉ាក់សាំងនេះផងដែរ។

ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B ត្រូវបានណែនាំចំពោះ **មនុស្សពេញវ័យ** ដែលមានហានិភ័យឆ្លងមេរោគជំងឺរលាកថ្លើមប្រភេទ B ដែលរួមបញ្ចូល៖
- មនុស្សដែលដៃគូរួមភេទកើតជំងឺរលាកថ្លើមប្រភេទ B
- មនុស្សដែលរួមភេទ ដែលមិនស្ថិតក្នុងទំនាក់ទំនងយូរអង្វែងមួយទល់មួយ
- មនុស្សដែលស្នើសុំការវាយតម្លៃ ឬការព្យាបាលចំពោះជំងឺឆ្លងតាមការរួមភេទ
- បុរសដែលរួមភេទជាមួយបុរសដទៃទៀត
- មនុស្សដែលប្រើម្ជុល ស៊ីរ៉ាំង ឬគ្រឿងបរិក្ខាចាក់ថ្នាំដទៃទៀតរួមគ្នា
- មនុស្សដែលប៉ះពាល់នឹងសមាជិកគ្រួសារ ដែលឆ្លងមេរោគជំងឺរលាកថ្លើមប្រភេទ B
- បុគ្គលិកថែទាំសុខភាព និងសុវត្ថិភាពសាធារណៈ ដែលមានហានិភ័យប៉ះពាល់ឈាម ឬវត្ថុរាវនៃរាងកាយ
- អ្នកស្នាក់នៅ និងបុគ្គលិកនៃអគារសម្រាប់អ្នកមានពិការផ្នែកលូតលាស់
- បុគ្គលក្នុងមណ្ឌលកែប្រែ
- ជនរងគ្រោះដោយសារការវាយប្រហារ ឬបំពានផ្លូវភេទ
- អ្នកធ្វើដំណើរ ទៅតំបន់ ដែលមានអត្រាកើតជំងឺរលាកថ្លើមប្រភេទ B ខ្ពស់
- មនុស្សកើតជំងឺថ្លើមរ៉ាំរ៉ៃ ជំងឺតម្រងនោម ផ្ទុកមេរោគអេដស៍ ឬជំងឺទឹកនោមផ្អែម
- នរណាម្នាក់ដែលចង់ការពារខ្លួនចំពោះជំងឺរលាកថ្លើមប្រភេទ B

គេពុំដឹងពីហានិភ័យចំពោះការទទួលថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B ក្នុងពេលដំណាលគ្នានឹងថ្នាំវ៉ាក់សាំងដទៃទៀតឡើយ។



U.S. Department of Health and Human Services
Centers for Disease Control and Prevention

## 3 មនុស្សមួយចំនួនមិនគួរទទួលថ្នាំវ៉ាក់សាំងនេះ។

សូមប្រាប់អ្នកដែលផ្តល់ថ្នាំវ៉ាក់សាំងដល់លោកអ្នកៈ

- **ប្រសិនបើបុគ្គល ដែលទទួលថ្នាំវ៉ាក់សាំង មានបញ្ហាអាឡាក់ស៊ីធ្ងន់ធ្ងរ ដែលគំរាមកំហែងដល់អាយុជីវិត។**
  ប្រសិនបើលោកអ្នកធ្លាប់មានប្រតិកម្មអាឡាក់ស៊ីដែលគំរាមកំហែងដល់អាយុជីវិត បន្ទាប់ពីបានទទួលដូសថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B ឬមានបញ្ហាអាឡាក់ស៊ីធ្ងន់ធ្ងរចំពោះធាតុផ្សំណាមួយនៃថ្នាំវ៉ាក់សាំងនេះ លោកអ្នកអាចត្រូវបានណែនាំកុំឲ្យចាក់ថ្នាំវ៉ាក់សាំងនេះ។ សូមសួរនាំអ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នក ប្រសិនបើលោកអ្នកចង់បានព័ត៌មានអំពីធាតុផ្សំនៃថ្នាំវ៉ាក់សាំង។
- **ប្រសិនបើបុគ្គល ដែលទទួលថ្នាំវ៉ាក់សាំង មានសុខភាពមិនស្រួលទេ។**
  ប្រសិនបើលោកអ្នកមានជំងឺឈឺស្រាល ដូចជា ជំងឺផ្តាសាយ លោកអ្នកប្រហែលអាចទទួលបានថ្នាំវ៉ាក់សាំងនៅថ្ងៃនេះ។ ប្រសិនបើលោកអ្នកមានជំងឺឈឺមធ្យម ឬធ្ងន់ធ្ងរ លោកអ្នកគួរប្រហែលរង់ចាំ រហូតទាល់តែលោកអ្នកជាសះស្បើយវិញ។ វេជ្ជបណ្ឌិតរបស់លោកអ្នកអាចផ្តល់យោបល់លោកអ្នក។

## 4 ហានិភ័យកើតប្រតិកម្មថ្នាំវ៉ាក់សាំង

ដូចថ្នាំដទៃទៀតដែរ រាប់ទាំងថ្នាំវ៉ាក់សាំង ឱកាសនៃការទទួលរងផលរំខាន អាចកើតមាន។ ជាធម្មតា ផលរំខានទាំងនេះ មានកម្រិតស្រាល ហើយបាត់ទៅវិញដោយខ្លួនឯង ប៉ុន្តែប្រតិកម្មធ្ងន់ធ្ងរក៏អាចកើតឡើងផងដែរ។

មនុស្សភាគច្រើនដែលទទួលថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B ពុំមានបញ្ហាជាមួយនឹងថ្នាំវ៉ាក់សាំងទេ។

**បញ្ហាស្រាល** បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B រួមមាន៖

- ការឈឺចាប់នៅកន្លែងចាក់ថ្នាំ
- សីតុណ្ហភាព 37.7°C (99.9°F) ឬខ្ពស់ជាងនេះ

ប្រសិនបើបញ្ហាទាំងនេះកើតឡើង ជាធម្មតា បញ្ហាទាំងនេះចាប់ផ្តើមកើតឡើងភ្លាមៗ បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង ហើយបន្តកើតឡើងសម្រាប់រយៈពេល 1 ឬ 2 ថ្ងៃ។

វេជ្ជបណ្ឌិតរបស់លោកអ្នកអាចប្រាប់លោកអ្នកបន្ថែមអំពីប្រតិកម្មទាំងនេះ។

**បញ្ហាដទៃទៀតដែលអាចកើតឡើង បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំងណាក៏ដោយ៖**

- ពេលខ្លះ មនុស្សសន្លប់ បន្ទាប់ពីដំណើរការវេជ្ជសាស្ត្រមួយដែលរួមបញ្ចូលទាំងការចាក់ថ្នាំវ៉ាក់សាំង។ ការអង្គុយ ឬដេកប្រហែល 15 នាទីបន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំងអាចជួយបង្ការការសន្លប់ និងរបួសដោយសារដួលបាន។ សូមប្រាប់អ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នក ប្រសិនបើលោកអ្នកវិលមុខ ឬចក្ខុញ្ញាណផ្លាស់ប្តូរ ឬឮសំឡេងហឹងក្នុងត្រចៀក។
- មនុស្សមួយចំនួនឈឺស្មារ ដែលអាចកាន់តែធ្ងន់ធ្ងរ និងកើតឡើងសម្រាប់រយៈពេលយូរ ជាការឈឺចាប់ធម្មតា ក្រោយពេលចាប់ថ្នាំ។ ករណីនេះកម្រកើតឡើងណាស់។
- ថ្នាំណាក៏ដោយក៏អាចបង្កប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ។ ប្រតិកម្មអាឡាក់ស៊ីទាំងនេះ ដោយសារតែថ្នាំវ៉ាក់សាំង គឺជាបញ្ហាកម្រ ដែលតាមការប៉ាន់ប្រមាណ មានតិចជាង 1 ក្នុងមួយលានដូស ហើយនឹងកើតឡើងក្នុងរយៈពេលពីរបីនាទីទៅពីរបីម៉ោង បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង។

ដូចថ្នាំផ្សេងទៀតដែរ ថ្នាំវ៉ាក់សាំងកម្រនឹងបង្ករបួសធ្ងន់ធ្ងរ ឬធ្វើឲ្យស្លាប់បាត់បង់ជីវិតណាស់។

សុវត្ថិភាពនៃថ្នាំវ៉ាក់សាំងតែងតែស្ថិតក្រោមការតាមដាន។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ៖
**www.cdc.gov/vaccinesafety/**

## 5 ចុះបើមានបញ្ហាធ្ងន់ធ្ងរ?

**តើខ្ញុំគួរប្រយ័ត្នចំពោះអ្វីខ្លះ?**

- សូមប្រយ័ត្នចំពោះអ្វីដែលធ្វើឲ្យលោកអ្នកព្រួយបារម្ភ ដូចជាសញ្ញាបង្ហាញពីប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ គ្រុនក្តៅខ្លាំង ឬឥរិយាបថខុសធម្មតា។

  សញ្ញាបង្ហាញពី**ប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ** អាចរួមបញ្ចូលកន្ទួរហើមមុខ និងបំពង់ក ពិបាកដកដង្ហើម ចង្វាក់បេះដូងញាប់ វិលមុខ និងកម្លាំងចុះខ្សោយ។ បញ្ហាទាំងនេះនឹងចាប់ផ្តើមកើតឡើងរយៈពេលពីរបីនាទីទៅពីរបីម៉ោងប៉ុណ្ណោះបន្ទាប់ពីការចាក់ថ្នាំវ៉ាក់សាំង។

**តើខ្ញុំគួរធ្វើអ្វីខ្លះ?**

- ប្រសិនបើលោកអ្នកគិតថា វាគឺជា**ប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ** ឬស្ថានការណ៍សង្គ្រោះបន្ទាន់ដទៃទៀតដែលមិនអាចរង់ចាំបាន សូមទូរស័ព្ទទៅ 9-1-1 ឬទៅកាន់មន្ទីរពេទ្យដែលជិតបំផុត។ បើមិនដូច្នោះទេ សូមទូរស័ព្ទទៅគ្លីនិករបស់លោកអ្នក។ ក្រោយមក ប្រតិកម្មគួររាយការណ៍ទៅ Vaccine Adverse Event Reporting System (ប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំង) (VAERS)។ វេជ្ជបណ្ឌិតរបស់លោកអ្នកអាចដាក់បញ្ជូនរបាយការណ៍នេះ ឬលោកអ្នកអាចរាយការណ៍ដោយផ្ទាល់តាមរយៈគេហទំព័រ VAERS នៅ **www.vaers.hhs.gov** ឬដោយការហៅទូរស័ព្ទមកលេខ **1-800-822-7967**។

*VAERS មិនផ្តល់យោបល់វេជ្ជសាស្ត្រទេ។*

## 6 កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង

National Vaccine Injury Compensation Program (កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង) (VICP) គឺជាកម្មវិធីរបស់រដ្ឋសហព័ន្ធ ដែលបានបង្កើតឡើងដើម្បីបង់សងអ្នកទាំងឡាយដែលអាចរងរបួសដោយសារតែថ្នាំវ៉ាក់សាំងមួយចំនួន។

បុគ្គលដែលជឿជាក់ថា ខ្លួនអាចធ្លាប់រងរបួសដោយសារថ្នាំវ៉ាក់សាំងមួយអាចធ្វើការសិក្សាអំពីកម្មវិធី និងអំពីការដាក់ពាក្យទាមទារសំណង ដោយទូរស័ព្ទមក **1-800-338-2382** ឬចូលទៅវេបសាយ VICP តាម **www.hrsa.gov/vaccinecompensation**។ មានរយៈពេលកំណត់សម្រាប់ការដាក់ពាក្យទាមទារសំណង។

## 7 តើខ្ញុំអាចសិក្សាបន្ថែមទៀតដោយរបៀបណា?

- សូមសួរអ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នក។ គាត់អាចផ្តល់ឯកសារក្នុងកញ្ចប់ថ្នាំវ៉ាក់សាំង ឬប្រាប់ប្រភពព័ត៌មានផ្សេងដល់លោកអ្នក។
- សូមទូរស័ព្ទទៅក្រសួងសុខាភិបាលរដ្ឋ ឬនៅមូលដ្ឋានរបស់លោកអ្នក។
- សូមទាក់ទង Centers for Disease Control and Prevention (មជ្ឈមណ្ឌលទប់ស្កាត់ និង បង្ការជំងឺ) (CDC)៖
  - ទូរស័ព្ទមកលេខ **1-800-232-4636 (1-800-CDC-INFO)** ឬ
  - ចូលទៅវេបសាយ CDC តាម **www.cdc.gov/vaccines**

DCH-0450CA AUTH: P. H. S., Act 42, Sect. 2126.

Vaccine Information Statement
Hepatitis B Vaccine
Khmer

Office use only

10/12/2018 | 42 U.S.C. § 300aa-26

Translation provided by the Immunization Action Coalition

Cambodian

ដើម្បីអនុញ្ញាតឲ្យអ្នកផ្តល់ការព្យាបាលសុខភាពស្នើសុំនូវពត៌មានអំពីការចាក់ថ្នាំបង្ការរោគពេញលក្ខណត្រឹមត្រូវ, ការពិនិត្យមើលនៃការចាក់ថ្នាំបង្ការរោគ ហើយនិងការតម្រូវដាក់ពេលវេលា សំរាប់ចាក់ថ្នាំបង្ការរោគនៅអនាគត, ពត៌មានអំពីការចាក់បង្ការរោគនឹងផ្ញើទៅមន្ទីរ Michigan Care Improvement Registry ។ បុគ្គលទាំងឡាយមានសិទ្ធិស្នើសុំអោយអ្នកផ្តល់ការព្យាបាលសុខ ភាពមិនអោយបញ្ជូនពត៌មានអំពីការចាក់ថ្នាំបង្ការរោគនេះទៅឲ្យកន្លែងទុកសំណុំរឿងបាន។